អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១០

## សេចក្តីប្រកាសព័ត៌មាន

## ថវិកាដែលបានយល់ព្រមដោយប្រទេសផ្តល់ជំនួយ សម្រាប់ឆ្នាំ ២០១០-២០១១ ត្រូវបានប្រកាសជាសាធារណៈ

សំណើរថវិកាចុងក្រោយបង្អស់ ដែលបានអនុម័តដោយប្រទេសផ្តល់ជំនួយ ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) សម្រាប់ឆ្នាំ ២០១០ និង២០១១ ត្រូវបានផ្សព្វផ្សាយជាផ្លូវការនៅក្នុងទីក្រុង New York ហើយឯកសារទាំងនេះ បានដាក់នៅលើគេហទំព័ររបស់ អ.វ.ត.ក។

ថវិកាដែលបានយល់ព្រមផ្តល់ឲ្យ សម្រាប់ឆ្នាំ ២០១០ - ២០១១ មានចំនួនសរុប ៨៧.១ លានដុល្លារសហរដ្ឋអាមេរិក ដែលថវិកាចំនួន ៤២.៩ លានដុល្លារសម្រាប់ឆ្នាំ២០១០ និងថវិកាចំនួន ៤៤.២ លានដុល្លារ សម្រាប់ឆ្នាំ២០១១។
ថវិកាសរុបសម្រាប់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានចំនួន ៦៥.៤ លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះ ថវិកាចំនួន ៣២.២ លានដុល្លារ សម្រាប់ឆ្នាំ២០១០ និងថវិកាចំនួន ៣៣.២ លានដុល្លារ សម្រាប់ឆ្នាំ២០១១ ។
ចំណែកថវិកាសម្រាប់ភាគីកម្ពុជានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញ មានចំនួន ២១.៧ លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះ ថវិកាចំនួន ១០.៧ លានដុល្លារ សម្រាប់ឆ្នាំ២០១០ និងថវិកាចំនួន ១១ លានដុល្លារ សម្រាប់ឆ្នាំ២០១១ ។ រាល់ចំនួនថវិកាសរុបទាំងអស់ មិនបានបូកបញ្ចូលថវិកាបម្រុងឡើយ។

បណ្តាប្រទេសផ្តល់ជំនួយ បានអនុម័តយល់ព្រមលើសំណើរថវិកាចុងក្រោយបង្អស់កាលពីដើមសប្តាហ៍នេះ ហើយសំណើរថវិកាដែលបានអនុម័តចុងក្រោយនេះ មានចំនួនខុសគ្នាខ្លះទៅនឹងសំណើរថវិកា ដែលបានដាក់បង្ហាញជូនគណៈកម្មាការនៃអង្គការសហប្រជាជាតិគាំទ្រការកាត់ក្តីរបស់តុលាការខ្មែរក្រហម (UNAKRT) និង បណ្តាប្រទេសជាមិត្ត(GIS) របស់អ.វ.ត.ក កាលពីខែ ធ្នូ ឆ្នាំ ២០០៩ ។

សំណើរថវិកាដែលបានអនុម័តទាំងនេះ អាចទាញយកបានពីគេហទំព័ររបស់ អ.វ.ត.ក:
http://www.eccc.gov.kh/english/annual_reports.aspx

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:

លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោក **ឌីម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 0៩៤
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី **យូកូ មេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណ:
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិច maeday@un.org